ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ELECTRICITE DU CAMBODGE

អគ្គិសនីកម្ពុជា

លេខ: ១១០៣ អជគ. អក.រប

# សេចក្ដីជូនដំណឹង
## ស្ដីពី ការជ្រើសរើសបុគ្គលិក

អគ្គិសនីកម្ពុជា សូមជម្រាបជូនដំណឹងដល់សាធារណៈជនថា អគ្គិសនីកម្ពុជា ត្រូវការជ្រើសរើសបុគ្គលិក **ចំនួន៤៤រូប** ដើម្បីចូលបម្រើការងារនៅតាមបណ្ដាអង្គភាព-អគ្គិសនីខេត្ត នៃអគ្គិសនីកម្ពុជា ដូចខាងក្រោម :

*- **លក្ខណៈសម្បត្តិបេក្ខជន** :

**១-បុគ្គលិកប្រចាំការវេន** ចំនួន៤១រូប សម្រាប់**បណ្ដាអនុស្ថានីយ នៅអង្គភាពអនុស្ថានីយ នៃនាយកដ្ឋានបញ្ជូនអគ្គិសនី** :

- អនុស្ថានីយអគ្គិសនីព្រៃទទឹង (GS4) ចំនួន០១រូប
- អនុស្ថានីយអគ្គិសនីអូរសោម (GS22) ចំនួន០១រូប
- អនុស្ថានីយអគ្គិសនីតាតៃ (GS25) ចំនួន០៣រូប
- អនុស្ថានីយអគ្គិសនីឃ្លាំងលើ (GS27) ចំនួន០១រូប
- អនុស្ថានីយអគ្គិសនីព្រះវិហារ (GS36) ចំនួន០៤រូប
- អនុស្ថានីយអគ្គិសនីកំពង់ធំ (GS40) ចំនួន០៤រូប
- អនុស្ថានីយអគ្គិសនីឧត្តរមានជ័យ (GS41) ចំនួន០១រូប
- អនុស្ថានីយអគ្គិសនីរាម (GS42) ចំនួន០១រូប
- អនុស្ថានីយអគ្គិសនីចំការហ្លួង (GS43) ចំនួន០៣រូប
- អនុស្ថានីយអគ្គិសនីល្វាឯម (GS47) ចំនួន០៣រូប
- អនុស្ថានីយអគ្គិសនីខ្សាច់កណ្ដាល (GS56) ចំនួន០១រូប
- អនុស្ថានីយអគ្គិសនីប៉ៃលិន (GS67) ចំនួន០១រូប
- អនុស្ថានីយអគ្គិសនីភ្នំពេញថ្មី (GS70) ចំនួន០៤រូប
- អនុស្ថានីយអគ្គិសនីកណ្ដាលស្ទឹង (GS79) ចំនួន០៤រូប
- អនុស្ថានីយអគ្គិសនីស្វាយលើ (GS94) ចំនួន០៦រូប
- អនុស្ថានីយអគ្គិសនីបាណន់ (GS95) ចំនួន០៣រូប

+បេក្ខជនទាំង០២ភេទ, មានអាយុចាប់ពី១៨ឆ្នាំ ដល់៣៥ឆ្នាំ
+បៀវត្សរ៍ផ្ដល់ជូន : បៀវត្សរ៍សុទ្ធ E.III.១ ក្នុងពេលសាកល្បងការងារ០៣ខែទទួលបាន៩០%
+កម្រិតជំនាញ : បញ្ចប់ការសិក្សាសញ្ញាប័ត្រមធ្យមបច្ចេកទេសអគ្គិសនីឡើងទៅ។

**២-ភ្នាក់ងារថែទាំបណ្ដាញMV-LV ស្នាក់ការក្រញូងសែនជ័យ** ចំនួន០១រូប សម្រាប់**អគ្គិសនីក្រចេះ** :

+បេក្ខជនភេទប្រុស, មានអាយុចាប់ពី១៨ឆ្នាំ ដល់៣៥ឆ្នាំ
+បៀវត្សរ៍ផ្ដល់ជូន : បៀវត្សរ៍សុទ្ធ E.III.១ ក្នុងពេលសាកល្បងការងារ០៣ខែទទួលបាន៩០%
+កម្រិតជំនាញ : បញ្ចប់ការសិក្សាសញ្ញាប័ត្រមធ្យមបច្ចេកទេសអគ្គិសនីឡើងទៅ។

៣-ភ្នាក់ងារស្រង់ថាមពល សាខាពញាក្រែក ចំនួន០១រូប និងជាងបន្តចរន្តនិងថែទាំជួសជុល សាខាមេមត់ ចំនួន០១រូប សម្រាប់**អគ្គិសនីត្បូងឃ្មុំ** :

+បេក្ខជនភេទប្រុស, មានអាយុចាប់ពី១៨ឆ្នាំ ដល់៣៥ឆ្នាំ

+បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E.III.១ ក្នុងពេលសាកល្បងការងារ០៣ខែទទួលបាន៩០%

+កម្រិតជំនាញ : បញ្ចប់ការសិក្សាសញ្ញាប័ត្រមធ្យមបច្ចេកទេសអគ្គិសនីឡើងទៅ។

*- ពាក្យសុំចូលប្រឡងដើម្បីបម្រើការងារនៅអគ្គិសនីកម្ពុជាបេក្ខជនត្រូវទាញយក(**Download**) ដោយផ្ទាល់ពីក្នុងគេហទំព័ររបស់អគ្គិសនីកម្ពុជា គឺ : **www.EDC.com.kh** ត្រង់ចំណុចព័ត៌មានវិជ្ជាជីវៈ ដោយចុចលើពាក្យសុំចូលប្រឡងដើម្បីបម្រើការងារនៅអគ្គិសនីកម្ពុជា។

*- បេក្ខជនត្រូវបំពេញពាក្យសុំចូលបម្រើការងារ និងត្រូវអញ្ជើញមកដាក់ពាក្យប្រឡងដោយផ្ទាល់ខ្លួន និងភ្ជាប់មកជាមួយនូវអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ច្បាប់ដើមមកជាមួយ។ ករណី បេក្ខជនមិនបានអញ្ជើញមកដាក់ពាក្យដោយផ្ទាល់ទេ អគ្គិសនីកម្ពុជា មិនទទួលពាក្យជូនឡើយ។

*- **<u>បេក្ខជនត្រូវមកដាក់ពាក្យ និងភ្ជាប់មកជាមួយនូវ</u>** :

| | |
|---|---|
| - ពាក្យសុំចូលប្រឡងដើម្បីបម្រើការងារ នៅអគ្គិសនីកម្ពុជា | ចំនួន ០១ ច្បាប់ |
| - ប្រវត្តិរូបសង្ខេប មានបិទរូបថត ៤ x ៦ | ចំនួន ០១ ច្បាប់ |
| - កិច្ចសន្យាសម្រាប់បំពេញពាក្យសុំចូលបម្រើការងារ និងកិច្ចសន្យាការងារ | ចំនួន ០១ ច្បាប់ |
| - សលាកប័ត្របេក្ខជន | ចំនួន ០១ ច្បាប់ |
| - ច្បាប់ចម្លងសញ្ញាប័ត្រចំណេះដឹងទូទៅ និងសញ្ញាប័ត្រជំនាញ | ចំនួន ០១ ច្បាប់ |
| - តារាងពិន្ទុ (TRANSCRIPT) | ចំនួន ០១ ច្បាប់ |
| - ច្បាប់ដើម និងច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន | ចំនួន ០១ ច្បាប់ |

*- ចំពោះបែបបទមួយចំនួនទៀត ដូចមានចែងក្នុងឧបសម្ព័ន្ធI នៃលក្ខន្តិកៈបុគ្គលិកអគ្គិសនីកម្ពុជា បេក្ខជនប្រឡងជាប់ មានកាតព្វកិច្ចបំពេញបន្ថែម។

*- **ទីកន្លែងទទួលពាក្យ** : សាលប្រជុំនាយកដ្ឋានរដ្ឋបាល នៅកីឡដ្ឋានបាល់ទាត់អគ្គិសនីកម្ពុជា (អតីតរោងចក្រអគ្គិសនីទី៤)។

ចាប់ពីថ្ងៃផ្សាយដំណឹងនេះ ហូតដល់ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣ រៀងរាល់ថ្ងៃធ្វើការ
<u>ពេលព្រឹក</u> ចាប់ពីម៉ោង ០៨ : ០០ ដល់ម៉ោង ១១ : ៣០ <u>ពេលល្ងាច</u> ចាប់ពីម៉ោង ១៤ : ០០ ដល់ម៉ោង ១៧ : ០០។

*- **ព័ត៌មានផ្សេងៗ** : សូមអញ្ជើញមកទាក់ទង ការិយាល័យរដ្ឋបាល ទីស្នាក់ការកណ្តាល អគ្គិសនីកម្ពុជា ឬតាមរយៈលេខទូរស័ព្ទ ០២៣ ៧២៣ ៩៧១ និង ០២៣ ៧២៤ ៧៧១។

ថ្ងៃ អង្គារ ០៧កើត ខែ ផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០២៣

ជ. **រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**អគ្គនាយកអគ្គិសនីកម្ពុជា**
**អគ្គនាយករង**

ELECTRICITE DU CAMBODGE

**អេង_គន្ធា**

**<u>បញ្ជាក់</u>**

- សេចក្តីជូនដំណឹងនេះ ធ្វើការផ្សព្វផ្សាយជាផ្លូវការតាមរយៈគេហទំព័ររបស់អគ្គិសនីកម្ពុជា គឺ : www.EDC.com.kh ត្រង់ចំណុច " ព័ត៌មានវិជ្ជាជីវៈ " ។